archive.today
webpage capture
Saved from http://m.freshnewsasia.com/index.php/en/business/219540-2021-11-12-05-1 search
no other snapshots from this url
24 Mar 2022 03:01:00 UTC
All snapshots from host m.freshnewsasia.com
Webpage Screenshot
share download .zip report bug or abuse donate










# គម្រោងវិនិយោគថ្មីៗចំនួន១៤ទៀត សរុបទុនវិនិយោគជាង៥៤៤លានដុល្លារ ត្រូវបានអនុម័តឲ្យដំណើរការ

2021-11-12 12:10pm

**(ភ្នំពេញ)៖** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ទើបតែអនុម័តគម្រោងវិនិយោគថ្មីៗចំនួន១៤ទៀត សរុបទុនវិនិយោគប្រមាណជាង៥៤៤លានដុល្លារ និងអាចបង្កើតការងារបានជាច្រើនពាន់កន្លែង។

**គម្រោងវិនិយោគថ្មីៗ ចំនួន១៤នេះ រួមមាន៖**

* គម្រោងរោងចក្រផ្គុំ និងដំឡើងរថយន្ត ចំនួន២គម្រោង សរុបទុនវិនិយោគ ៣៧.៣លានដុល្លារអាមេរិក
* គម្រោងសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី ចំនួន២គម្រោង សរុបទុនវិនិយោគ ៤៤១លានដុល្លារអាមេរិក
* គម្រោងបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ និងផលិតកាបូប ចំនួន៧ម្រោង សរុបទុនវិនិយោគ ៣៤.៧លានដុល្លារអាមេរិក
* គម្រោងបង្កើតរោងចក្រកែច្នៃផ្លែឈើ, ផលិតទឹកបរិសុទ្ធ ផលិតពោងខ្យល់គ្រប់ប្រភេទ ចំនួន៣គម្រោង សរុបទុនវិនិយោគ ៣១.៨លានដុល្លារអាមេរិក។

**តាម Facebook ផ្លូវការរបស់ CDC បានចុះផ្សាយថា តាមសំណើសុំវិនិយោគរបស់ក្រុមហ៊ុន គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ជូនដល់ក្រុមហ៊ុនដូចខាងក្រោម៖**

**១៖** RMA AUTOMOTIVE (CAMBODIA) CO., LTD: គម្រោងបង្កើតរោងចក្រផ្គុំ និងដំឡើងរថយន្ត ដែលមានទីតាំងវិនិយោគស្ថិតនៅផ្លូវជាតិលេខ៥ ភូមិសារវ៉ែន ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ មានទុនវិនិយោគចំនួន ២១លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ៤៤១កន្លែង។

**២៖** EM AUTOMOBILE CO., LTD: គម្រោងបង្កើតរោងចក្រផ្គុំដំឡើងគ្រឿងចក្រ រថយន្តសណ្តោង និងរថយន្តដឹកទំនិញធុនធ្ងន់គ្រប់ប្រភេទ ដែលមានទីតាំងវិនិយោគស្ថិតនៅផ្លូវជាតិលេខ៤៨ ភូមិឈូក ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង មានទុនវិនិយោគចំនួន ១៦.៣លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ៥១៥កន្លែង។

៣៖ SCHNEITEC WESTERN CO., LTD: គម្រោងសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី ៥០០គីឡូវ៉ុល ពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃ មានទុនវិនិយោគប្រមាណ ១១១លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ៧៧កន្លែង។

៤៖ SCHNEITEC NORTHERN CO., LTD: គម្រោងសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី ៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ មានទុនវិនិយោគប្រមាណ ៣៣០លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ១៤០កន្លែង។

៥៖ SMART TEX GARMENT (CAMBODIA) CO., LTD: គម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានទុនវិនិយោគប្រមាណ ៦.៤លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ៣,៣៨០កន្លែង។

៦៖ REMONDA (CAMBODIA) APPAREL CO., LTD: គម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិអង្គស្នួលទី៣ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល មានទុនវិនិយោគប្រមាណ ២.៣លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន៨០៣កន្លែង។

៧៖ CATHAYA INDUSTRY (CAMBODIA) CO., LTD: គម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅផ្លូវជាតិលេខ៤៤ ភូមិសន្តិភាព ឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានទុនវិនិយោគប្រមាណ ៥.៥លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ១,៦៤៧កន្លែង។

៨៖ HENGWIN (CAMBODIA) GARMENT CO., LTD: គម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិក្រាំងគាំ ឃុំត្បែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មានទុនវិនិយោគប្រមាណ ៥.៤លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ១,៦៤៨កន្លែង។

៩៖ JW ZHONGRUN (CAMBODIA) GARMENT CO., LTD: គម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិកន្ទោកជើង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ មានទុនវិនិយោគប្រមាណ៤លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ១,៦៤៨កន្លែង។

១០៖ WTX LEADING FASHION CO., LTD: គម្រោងបង្កើតរោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ ដែលមានទីតាំងវិនិយោគស្ថិតនៅក្បាលដីលេខ០៩៩៤ ផ្លូវជាតិលេខ២១ ភូមិព្រែកខ្សេវ សង្កាត់កោះខ្សាស់ ក្រុងតាខ្មៅ ខេត្តកណ្តាល មានទុនវិនិយោគប្រមាណ៧លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ១,០៦១កន្លែង។

១១៖ CLOTHO (CAMBODIA) CO., LTD: គម្រោងបង្កើតរោងចក្រផលិតកាបូប ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានទុនវិនិយោគប្រមាណ ៤.១លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ១,០១៨កន្លែង។

១២៖ HUN TY REAL ESTATE CO., LTD: គម្រោងបង្កើតរោងចក្រកែច្នៃផ្លែឈើ និងផលិតសម្ភារវេចខ្ចប់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិវាល ឃុំកំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ មានទុនវិនិយោគប្រមាណ១៧.២លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន៤៣០កន្លែង។

១៣៖ KULARA WATER CO., LTD: គម្រោងបង្កើតរោងចក្រផលិតទឹកបរិសុទ្ធ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិស្រយង់ត្បូង ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ មានទុនវិនិយោគប្រមាណ ៥.៦លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ១០៧កន្លែង។

១៤៖ SUN PLEASURE (CAMBODIA) CO., LTD: គម្រោងបង្កើតរោងចក្រផលិតពោងខ្យល់គ្រប់ប្រភេទ ទូកកាយ៉ាក់ និងសម្ភារៈបរិក្ខាពាក់ព័ន្ធនឹងពោងគ្រប់ប្រភេទ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិព្រៃខ្លា ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល មានទុនវិនិយោគប្រមាណ៩លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ៦៤០កន្លែង៕




ប៉ុរី ឡេង ណារ៉ាត្រា 010 321 222, 012 321 222


ប្លង់បង្ហាញទីតាំងស្នើសុំរបស់ក្រុមហ៊ុន
WTX Leading Fashion Co., Ltd.
ភ្នំពេញ
ស្ពានលេខ៤
ស្ពានលេខ៥
ស្ពានលេខ៦
Fortune Garment & Woolen Knitting
ទីតាំងស្នើសុំ
សាលាស្រុកស្អាង

ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន

SMART TEX GARMENT (CAMBODIA) CO., LTD

(រោងចក្រកាត់ដេរសម្លៀកបំពាក់)



ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន

SUN PLEASURE (CAMBODIA) CO., LTD.

(រោងចក្រផលិតពោងខ្យល់គ្រប់ប្រភេទ ទូកកាយ៉ាក់ និងសម្ភារៈបរិក្ខារពាក់ព័ន្ធនឹងពោងគ្រប់ប្រភេទ)




ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន

R M A AUTOMOTIVE (CAMBODIA) CO., LTD.

( រោងចក្រផ្គុំដំឡើងរថយន្ត ផលិត ចែកចាយ លក់ និងសេវាកម្ម )



## ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន

SCHNEITEC WESTERN CO., LTD.

(សាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី ៥០០គីឡូវ៉ុល ពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃ)




## ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន

KULARA WATER CO., LTD.

(រោងចក្រផលិតទឹកបរិសុទ្ធ)



**ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន**

**REMONDA (CAMBODIA) APPAREL CO., LTD**

(រោងចក្រកាត់ដេរសម្លៀកបំពាក់)



**ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន**

SCHNEITEC NORTHERN CO., LTD.

(គម្រោងសាងសង់ខ្សែបណ្ដាញបញ្ជូនអគ្គិសនី តង់ស្យុង ៥០០ គីឡូវ៉ុល ពីរាជធានីភ្នំពេញ
ទៅព្រំដែនកម្ពុជា- ឡាវ កាត់ខេត្តកណ្ដាល កំពង់ចាម កំពង់ធំ ស្ទឹងត្រែង និងខេត្តព្រះវិហារ ប្រវែង ២៩៩,៥២ គ.ម)




ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន
JW ZHONGRUN (CAMBODIA) GARMENT CO., LTD.
(កាត់ដេរសម្លៀកបំពាក់)
ផ្សារសែនមនោរម្យច្រកទី២
ផ្សារសែនមនោរម្យច្រកទី១
ស្ពានអាកាសចោមចៅ
កំពង់ស្ពឺ
TOTAL
២.៧ គ.ម
គ.ម ១៥
SOKIMEX
រ.ច Im Soo Apparel
បុរីសែនមនោរម្យ
រ.ច Dong Lei
(Cambodia) Plastic
Dong Kwang Global Co., Ltd.
រ.ច Cambo Handsome Ltd
រ.ច EASETEX
(CAMBODIA) CO., LTD.
ឃ្លាំងទំនេរ
ទីតាំងស្នើសុំ
រ.ច QY BAG & LUGGAGE
(CAMBODIA) CO., LTD.


ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន
HUN TY REAL ESTATE CO., LTD
(រោងចក្រកែច្នៃផ្លែឈើ និងផលិតសម្ភារៈវេចខ្ចប់)
ដីទំនេរ
ទីតាំងស្នើសុំ
ដីចំការ
ភ្នំពេញ
ក្រុងព្រះសីហនុ


ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន
EM AUTOMOBILE CO., LTD
(រោងចក្រផ្គុំដំឡើងគ្រឿងចក្រ រថយន្តសណ្តោង និងរថយន្តដឹកទំនិញធុនធ្ងន់គ្រប់ប្រភេទ)
ទីតាំងស្នើសុំ
ដីទំនេរ
ភ្នំពេញ
ក្រុងព្រះសីហនុ

## ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគថ្មីរបស់ក្រុមហ៊ុន

CLOTHO ( CAMBODIA ) CO., LTD

### រោងចក្រផលិតកាបូប





ប្លង់បង្ហាញទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន
CATHAYA INDUSTRY (CAMBODIA) CO., LTD
(រោងចក្រកាត់ដេរសម្លៀកបំពាក់)
ស្រុកឱរ៉ាល់
រមណីយដ្ឋាន
ភ្នំចាស់
១២ KM
ស្ពានច្បារមន
ដីឡូតិ៍
ទីតាំងស្នើសុំ
-១០ គ.ម-
ផ្លូវជាតិលេខ៤៤
២ គ.ម.
TELA
ទីរួមខេត្តកំពង់ស្ពឺ
ផ្លូវជាតិលេខ៤
ខេត្តព្រះសីហនុ
១.២០០ម
៤៨ KM

ប្លង់ទីតាំងស្នើសុំវិនិយោគរបស់ក្រុមហ៊ុន

HENGWIN (CAMBODIA) GARMENT CO., LTD

(រោងចក្រកាត់ដេរសម្លៀកបំពាក់)







ចេញដំណើរៀងរាល់ថ្ងៃ
ភ្នំពេញ ⇌ សៀមរាប
ភ្នំពេញ ⇌ ព្រះសីហនុ
ភ្នំពេញ ⇌ កំពត
កំពត ⇌ ព្រះសីហនុ
Larryta
011/016-20 20 20
Online Booking : www.larryta.com


9 នាទីពី AEON II
តម្លៃទាប ជាងទីផ្សារ!
ប្រាក់កក់ 0%
012 718 877 , 017 722 822 ,081 999 169


UNIVERSITY OF INDRAWICHEA
Study Camp
Study Exchange


中元节
089 334 555
070 999 381



Copyright © 2021 FN Media Co.,Ltd.

Data Center By Fresh News

